# ៦. ថ្នាក់ទី ១.៣

៦.១ គោលបំណងនៃកម្មវិធីសិក្សាអប់រំមូលដ្ឋានកំរិតបឋមសិក្សា "ថ្នាក់ទី១.៣ " គឺធានាថាសិស្សម្នាក់ៗមានមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរ និងគណិតវិទ្យា ព្រមទាំងបានអភិវឌ្ឍ សុខភាព កាយសម្បទា សីលធម៌ បំនិនសិក្សា និង បំនិនជីវិត។

៦.២ **កម្មវិធីសិក្សាជាតិ** នៅថ្នាក់ទី១.៣ នេះ មានមុខវិជ្ជាសិក្សា និង បំនែងចែកម៉ោងសិក្សាតាមមុខវិជ្ជានីមួយៗ ដែលមួយម៉ោងសិក្សាមានរយៈពេល ៤០នាទី ដូចខាងក្រោម :

| **មុខវិជ្ជាកម្មវិធីសិក្សាជាតិ** | **ចំនួនម៉ោងសិក្សាក្នុង១សប្តាហ៍** |
|---|---|
| ភាសាខ្មែរ | ១៣ |
| គណិតវិទ្យា | ៧ |
| វិទ្យាសាស្ត្រ និង សិក្សាសង្គម (រួមទាំងអប់រំសិល្បៈ) | ៣ |
| អប់រំកាយ និង សុខភាព | ២ |
| **សរុបម៉ោងសិក្សាកម្មវិធីសិក្សាជាតិ** | **២៥** |
| កម្មវិធីបំនិនជីវិតតាមមូលដ្ឋាន | ២ - ៥ |
| **សរុបម៉ោងសិក្សា** | **២៧ - ៣០** |

៦.៣ ការអប់រំសិល្បៈ (ចំរៀង គំនូរ របាំ តន្ត្រី ...) ត្រូវបញ្ចូលក្នុងមុខវិជ្ជា វិទ្យាសាស្ត្រ និងសិក្សាសង្គម ។